ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# សេចក្តីថ្លែងការណ៍

ខ្ញុំ **យន្ត ថារូ** អ្នកតំណាងរាស្រ្តមណ្ឌលបន្ទាយមានជ័យ ក្រោយពីបានឃើញ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បាននិមន្តចូលរួមជាព្រះអធិបតី នៅក្នុងពិធីបុណ្យដ៏ធំមួយនៅដែនដីកម្ពុជាក្រោម កាលពីថ្ងៃព្រហស្បតិ៍ ២រោជ ខែផល្គុន ឆ្នាំជូត សំរិទ្ធិស័ក ព.ស ២៥៥២ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ និង**ឯកឧត្តម ខៀវ កាញារីទ្ធ** រដ្ឋមន្រ្តីក្រសួងពត៌មាន បានដឹកនាំគណៈប្រតិភូទៅចូលរួមកាន់បិណ្ឌ នៅវត្តមួយចំនួននៃដែនដីកម្ពុជាក្រោម កាលពីថ្ងៃសៅរ៍ ១រោជ ខែភទ្របទ ឆ្នាំឆ្លូវ ឯកស័ក ព.ស ២៥៥៣ ត្រូវនឹងថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៩ ដោយមានការស្វាគមន៍ និងអបអរសាទរយ៉ាងក្រៃលែង ពីព្រះសង្ឃនិងបងប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោម ដែលកំពុងរស់នៅលើទឹកដីដូនតារបស់ខ្លួន ហើយរយៈពេលជាង៣០ឆ្នាំនេះ ខ្មែរកម្ពុជាក្រោម និងខ្មែរកណ្តាលពុំដែលបានទំនាក់ទំនងគ្នាជាផ្លូវការទេ។

ពាក្យថាកម្ពុជាក្រោម ពីថ្ងៃនេះតទៅលែងជាឧបសគ្គទៀតហើយ ពីព្រោះកន្លងមកពាក្យថាកម្ពុជាក្រោម ត្រូវបានរដ្ឋាភិបាលវៀតណាមហាមឃាត់ និងចោទប្រកាន់ ដោយឱ្យប្រើពាក្យថាខ្មែរណាមបូទៅវិញ។

សកម្មភាពទាំងអស់នេះ សបញ្ជាក់ឱ្យឃើញថា ខ្មែរចេះជួយខ្មែរ ខ្មែរចេះការពារខ្មែរ ខ្មែរចេះស្រឡាញ់កេរ្តិ៍ដំណែលពីដូនតារបស់ខ្លួន ។ ដូច្នេះខ្ញុំមានសេចក្តីត្រេកអរ និងរីករាយយ៉ាងក្រៃលែង ហើយមានក្តីសង្ឃឹមយ៉ាងមុតមាំថា ចាប់ពីនេះតទៅមុខ បងប្អូនជនរួមឈាមខ្មែរនៅឯដែនដីកម្ពុជាក្រោម នឹងត្រូវបានការយកចិត្តទុកដាក់ ពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំមានជំនឿថា បងប្អូនជនរួមឈាមខ្មែរ និងថ្នាក់ដឹកនាំនៃព្រះរាជាណាចក្រកម្ពុជា នឹងមានសកម្មភាពដ៏ល្អបែបនេះ ជាហូរហែបន្តទៅអនាគត ហើយការធ្វើបុណ្យក្តី ការទៅទេសចរណ៍ក្តី ការទៅទស្សនកិច្ចក៏ដោយ សូមឱ្យជួយនាំយកនូវសៀវភៅក្បួនខ្នាតជាអក្សរសាស្រ្តខ្មែរ ទៅចែកជូនដល់បងប្អូនជនរួមឈាមនៃយើង ដែលកំពុងរស់នៅឯដែនដីកម្ពុជាក្រោម សំរាប់ការសិក្សារៀនសូត្រ ដើម្បីជាឧត្តមប្រយោជន៍នៃមាតុភូមិរបស់យើង។

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩

**យន្ត ថារូ**

អ្នកតំណាងរាស្រ្តមណ្ឌលបន្ទាយមានជ័យ
០១១ ៩៧ ៨៥ ៨៣ / ០១២ ៤៨ ១១ ៦១



គេហទំព័រនៃសហគមន៍ខ្មែរកម្ពុជាក្រោម KhmerKromngo.org